ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គភាពសារព័ត៌មាន

វ៉ាវញូស៍ដេលី | WOW News Daily

លេខ ..................... W.N.D

# កិច្ចសន្យាការងារម៉ៅម៉ោង

កិច្ចព្រមព្រៀងនេះធ្វើឡើង

**រវាង**

ឈ្មោះ **ថៃ ស៊ានមុី** ភេទប្រុស អាយុ.........ឆ្នាំ អាស័យដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ១៧០J ផ្លូវលេខ១០៨ បុរីហុងឡាយ ភូមិថ្មគោល២ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ តួនាទីជា៖ ចាងហ្វាង នៃអង្គភាពសារព័ត៌មានវ៉ាវញូស៍ដេលី។ ហៅថា **ភាគី ក** ។

**និង**

ឈ្មោះ.................................................ភេទ...........អាយុ.........ឆ្នាំ អាស័យដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ........... ផ្លូវ.............ភូមិ......................ឃុំ/សង្កាត់....................ក្រុង/ស្រុក/ខណ្ឌ........................រាជធានី/ខេត្ត...................... ដែលមានតួនាទីជា ភ្នាក់ងារយកព័ត៌មាន។ ហៅថា **ភាគី ខ** ។

យោងតាមបទបញ្ជាផ្ទៃក្នុងរបស់ អង្គភាពសារព័ត៌មានវ៉ាវញូស៍ដេលី ។

**សម្រេច**

**ភារកិច្ចរបស់ ភាគី ក ៖**

១. ធានានូវភាពត្រឹមត្រូវរបស់ អង្គភាពសារព័ត៌មានវ៉ាវញូស៍ដេលី ស្របទៅតាមច្បាប់របបសារព័ត៌មាន ឆ្នាំ១៩៩៥ និងច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ។

២. ត្រូវមានការលើកទឹកចិត្ត ជាកម្រៃសេវាដើងសារតាមលិទ្ធភាពជាក់ស្តែង ក្នុងករណីដែល ភាគី ខ បាន ខិតខំយកព័ត៌មានផ្តល់មកឲ្យអង្គភាពចុះផ្សាយ ហើយទទួលបានការឧបត្ថម្ភ **(Sponsor)** ពីក្រុមហ៊ុន ឬស្ថាប័នណាមួយ ។

៣. ក្នុងករណីចាំបាច់ ឬពិសេសណាមួយត្រូវផ្តល់នូវគ្រឿងបរិក្ខារបច្ចេកទេសទៅឲ្យភាគី ខ សម្រាប់បម្រើឲ្យការយក ឬផ្សាយព័ត៌មាននោះ ។

**ភារកិច្ចរបស់ ភាគី ខ ៖**

១. គ្មានការលួចបន្លំ ឬកេងប្រវ័ញ្ចអ្វីមួយពីស្ថាប័ន។

២. ធ្វើការដោយអត់ធ្មត់ ស្មោះត្រង់ សុទិដ្ឋិនិយមមិនធេវធាវ និងមិនជេរស្តីប្រមាថលើអ្នកដទៃ ពិសេសលើក្រុមការងារក្នុងអង្គភាព ។

៣. រាល់ការសុំច្បាប់ឈប់សំរាកត្រូវរាយការណ៍អោយភាគី(ក)ដឹងជាមុនយ៉ាងហោចណាស់៣ថ្ងៃ។

៤. មានសាមគ្គីភាព ចេះយោគយល់អធ្យាស្រ័យគ្នាក្នុងពេលបំពេញការងារ។

៥. ធ្វើការរាយការណ៍ជាបន្ទាន់មកចាងហ្វាង ឬគណៈគ្រប់គ្រង ករណីគ្រឿងឧបករណ៍ប្រើប្រាស់មានបញ្ហាអ្វីមួយ។

៦. ប្រកាន់ភ្ជាប់នូវវប្បធម៌ការសន្ទនាគ្នា ដើម្បីរកដំណោះស្រាយពេលមានបញ្ហា (ជៀសវាងប្រើប្រាស់អំពើហិង្សា)។

៧. ត្រូវថេះថែរក្សា និងមើលការទទួលខុសត្រូវលើឧបករណ៍ដែលខ្លួនកំពុងប្រើប្រាស់និងគ្រប់គ្រងសព្វថ្ងៃ ក្នុងករណីមានចេតនាធ្វើឲ្យខូចខាតលើឧបករណ៍នោះ សាមីខ្លួន ត្រូវមានកាតព្វកិច្ចចេញថ្លៃសងការខូចខាតទាំងស្រុង ។

៨. មិនអនុញ្ញាតអោយយកប័ណ្ណសារព័ត៌មាន រឺឈ្មោះអង្គភាព ប្រើប្រាស់ក្នុងរូបភាពផ្ទុយពីច្បាប់ស្តីពីរបបសារព័ត៌មានកម្ពុជា ឆ្នាំ១៩៩៥ និងច្បាប់ពាក់ព័ន្ធផ្សេងៗ ។

៩. ករណីប្រព្រឹត្តអំពីពុករលួយ ឬចំរិតទារប្រាក់ពីប្រជាពលរដ្ឋ ឬស្ថាប័នផ្សេងៗ ផ្ទុយនឹងច្បាប់ជាតិ និងអន្តរជាតិ ត្រូវទទួលខុសត្រូវដោយខ្លួនឯង ចំពោះមុខផ្លូវច្បាប់ អង្គភាពយើងខ្ញុំមិនទទួលខុសត្រូវឡើយ។

១០. ការសុំឈប់សំរាក លាលែងពីការងារ ត្រូវរាយការណ៍ជូនដល់ ភាគី(ក) ដឹងជាមុនយ៉ាងហោចណាស់មុន១ខែ ហើយត្រូវប្រគល់ប័ណ្ណសារព័ត៌មាន និងសម្ភារៈឧបករណ៍បច្ចេកទេសរបស់អង្គភាព មកកាន់អង្គភាពវិញជាដាច់ខាត យ៉ាងយូរបំផុត រយៈពេល ១ខែ ក្រោយកាលបរិច្ឆេទនៃលិខិតសុំលាលែង របស់សាមីខ្លួននោះ ។

ករណីបុគ្គលដែលជាបុគ្គលិកខាងលើ ពុំបានគោរពនូវលក្ខខណ្ឌ **១០ចំណុច**ដែលបានរៀបរាប់ខាងលើនោះ អង្គភាពសារព័ត៌មានរ៉ាវញូស៍ដេលី មានសិទ្ធបញ្ឈប់ការងារ ឬមានចំណាត់ការតាមផ្លូវច្បាប់ជាធរមាន ដោយអង្គភាពពុំជូនដំណឹង និងប្រាប់អំពីមូលហេតុជាមុនឡើយ ។

**កិច្ចសន្យានេះមានសុពលភាពគិតត្រឹមចាប់ពីថ្ងៃចុះហត្ថលេខា និងផ្តិតស្នាមមេដៃនេះតទៅ។**

ថ្ងៃ.................................ខែ...................ឆ្នាំ......... .................ស័ក ព.ស២៥៦........

ធ្វើនៅ............................., ថ្ងៃទី..........ខែ.........ឆ្នាំ២០...........

**ស្នាមមេដៃស្តាំ ភាគី ក** **ស្នាមមេដៃសាក្សី** **ស្នាមមេដៃស្តាំ ភាគី ខ**